ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៤៧
ចុះថ្ងៃទី២០-១១-១៩៩៨

សាលដីកា
លេខ : ១៣
ចុះថ្ងៃទី២៣-៦-១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ប្រធាន
២- លោក យឹម ស៊ីផុង ចៅក្រម
៣- លោក សោម សិរីវឌ្ឍ ចៅក្រម
៤- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៥- លោក ឃាំ ស៊ូខឿន ចៅក្រម
លោក ប៊ុំ វណ្ណា ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក ជួន ស៊ុនឡេង ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ២៦-៨-១៩៩៨ ពីសាលដីកាព្រហ្មទណ្ឌ លេខ : ១៥៤ ចុះថ្ងៃទី១០-៧-១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២០-១១-១៩៩៨ របស់តុលាការកំពូល ។

ពីបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ៤-៤-១៩៩៦ តាមមាត្រា ៣៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ស្នូ ហ្វិន " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៣០ឆ្នាំ ជាតិ ហ្គាណា ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៣៥ ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ
- មេធាវី លោក អ៊ិត កុំ
- ដើមបណ្តឹងព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញ
- តាមរបាយការណ៍លេខ ០៨ , ៩៦របក ចុះថ្ងៃទី ០៤-៤-៩៦ ការិយាល័យបង្ក្រាបគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរាយការណ៍ជូនព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញថា : កាលពីថ្ងៃទី ០៤-៤-៩៦ វេលាម៉ោង ៥ ព្រឹក ការិយាល័យ យើងខ្ញុំបានចាប់ដាក់ស្លែងជនបរទេសជួញគ្រឿងញៀនចំនួន ១នាក់ នៅពេលកំពុងលក់គ្រឿងញៀននៅក្នុងផ្ទះជនជាប់ចោទស្នាក់នៅលេខ ៣៥អឺ១ពីរ ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញរាជធានីភ្នំពេញ ។

- បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ថា ៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស្មុ ហ៊ិន ភេទប្រុស អាយុ៣៣ឆ្នាំ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ព្រហ្មទណ្ឌអន្តរកាល តាមមាត្រា ៣៩ ។ ក្នុងនាមអយ្យការនៅតែរក្សាការចោទប្រកាន់ និង សូមអោយតុលាការផ្ដន្ទាទោសជនល្មើស ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១១ " ខ " ចុះថ្ងៃទី ២៥-០២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច ថា ៖

១- ផ្ដន្ទាទោសឈ្មោះ ស្មុ ហ៊ិន ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិហ្គាណា ដាក់ពន្ធនាគារតំរូវអោយធ្វើការកំណត់ ៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ បទល្មើសដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤-៤-១៩៩៦ ។

២- វត្ថុតាង មាន ៖

- មេដ្រាពណ៌ស ប្រភេទអង្ក្រមអាល់កាឡូយ៉ូ ទំងន់ ២០០ក្រាម មេដ្រាស ទំងន់ ៣០០ក្រាម និង កញ្ចប់តូចខ្ចប់ក្រដាសការ៉ែតត្រូវរឹបអូស និង បំផ្លាញចោល ។

- លិខិតឆ្លងដែនលេខ អា ៩៦០១៧២ និង អា ២៣១៨៦០

- កាតលេខ ១៧៣១៣៩៨៨

- ខ្សែក្រឈើ , ម្ហូរដេរស្បែកជើង ១ , ដុល្លាអាមេរិក ៥០ដុល្លា មានក្រដាស ២០ លេខ បេអ៊ែ១៣០៧៥៩៥ ក្រដាស ២០លេខ អេហ្វ ៩១៦១៨១១៣អា ក្រដាស ១០ លេខ បេ៣៧៨២៩៥៣៥ អា , កាបូបក្រវ៉ាត់ចង្កេះ ០១ , លិខិតផ្សេងៗ ០១ចំនួន , ទូរទស្សន៍ម៉ាកសូនី លេខ ១០១៦៩៥៦ ទំហំ ១១អ៊ីង ០១គ្រឿង , ម៉ាទៀម៉ាកសូនី សេរីអេហ្វអេស ៧១៥-១៣០វ៉ាត់ ត្រូវប្រគល់អោយឈ្មោះ ស្មុ ហ៊ិន វិញ ។

៣- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី ២៥-០២-១៩៩៧ របស់ឈ្មោះ ស្មុ ហ៊ិន ដែលប្ដឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ១១ " ខ " ចុះថ្ងៃទី ២៥-០២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា ៖ រក្សាបទចោទប្រកាន់ដូចតុលាការក្រោមដដែល ស្នើសុំក្រុមប្រឹក្សាជំនុំជំរះតំកល់សាលក្រមដើមទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី ១០-៧-១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចថា ៖

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥-០២-១៩៩៧ របស់ជនជាប់ចោទឈ្មោះ ស្មុ ហ៊ិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស និង គតិច្បាប់ ។

២- តំកល់សាលក្រមព្រហ្មទណ្ឌលេខ ១១ " ខ " ចុះថ្ងៃទី ២៥-០២-៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ២៦ - ៨ - ១៩៩៨ របស់ឈ្មោះ ស្មុ ហ៊ិន ដែលប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី ១០ - ៧ - ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី ១៩ - ០៩ - ១៩៩៩ របស់ឈ្មោះ ស្មុ ហ៊ិន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

១ - បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ ស្មុ ហ៊ិន ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យ ពិចារណា ។

២ - បដិសេធសាលដីកាលេខ ១៥៤ ចុះថ្ងៃទី ១០ - ៧ - ៩៨ របស់សាលាឧទ្ធរណ៍ ទុកជាមោឃៈ ។

- បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ ស្មុ ហ៊ិន : ខ្ញុំបាទពុំបានប្រព្រឹត្តបទល្មើសទេ នៅពេលប៉ូលីសចុះមកឆែកឆេរផ្ទះរបស់ខ្ញុំ ខ្ញុំឃើញប៉ូលីសម្នាក់យកកញ្ចប់ម្សៅសមកទំលាក់ក្នុងផ្ទះខ្ញុំ ហើយប៉ូលីសឯទៀតធ្វើការឆែកឆេរ ឃើញកញ្ចប់នេះ ក៏ចាប់ខ្លួនខ្ញុំតែម្តងដោយគ្មានដីកាចាប់ខ្លួន និង ដីកាឆែកឆេរ ពីតុលាការឡើយ ។ សូមតុលាការមេត្តាដោះលែង ខ្ញុំបាទអោយមានសេរីភាពដូចគេឯងផង ។

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវី លោក អ៊ិត ភុំ ការពារអោយជនជាប់ចោទ: ឈ្មោះ ស្មុ ហ៊ិន សុំបដិសេធព្រោះខ្លួនពុំបានប្រព្រឹត្តទេ ម៉្យាងទៀត ស្មុ ហ៊ិន ជាជនជាតិហ្គាណា គឺគ្មានស្ថានទូតនៅប្រទេសខ្មែរជាអ្នកជួយដោះស្រាយរកខុសត្រូវទេ ហើយការដាក់បន្ទុកមកលើ ស្មុ ហ៊ិន តាមរយ: អាដាម អោយប៉ូលីសមកចាប់ខ្លួន ស្មុ ហ៊ិន តែម្តងគ្មានដីកាចាប់ខ្លួនទេ ។ ដូច្នេះសូមតុលាការដោះលែង ដោយអនុគ្រោះ ។

- តំណាងមហាអយ្យការគ្មានអ្វីបន្ថែមទេសូមរក្សាសេចក្តីសន្និដ្ឋានដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ សេចក្តីសន្និដ្ឋានរបស់មេធាវី ជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ស្មុ ហ៊ិន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាម

មាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- ដោយឃើញថា ការដែលតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍ សំរេចផ្ដន្ទាទោស ឈ្មោះ ស្នេ ហ៊ិន ដាក់ពន្ធនាគារតំរូវអោយធ្វើការកំណត់ ៥ឆ្នាំ ពីបទ ជួញ គ្រឿងញៀន ខុសច្បាប់ ដោយអាងហេតុថា មានភស្តុតាងគ្រប់គ្រាន់នោះ គឺជាការភ័ន្តច្រឡំពីព្រោះថា:

. ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាឈ្មោះ ស្នេ ហ៊ិនកំពុងលក់គ្រឿងញៀន នៅក្នុងផ្ទះរបស់ខ្លួនឡើយ ។

. ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជាអំពើល្មើសជាក់ស្ដែងឡើយ ។

. ការឆែកឆេរលំនៅដ្ឋានរបស់ ឈ្មោះ ស្នេ ហ៊ិន ពុំមានដីកាពីអាជ្ញាធរ តុលាការទេ និងពុំបានធ្វើនៅចំពោះមុខសាក្សីដែលជាការរំលោភទៅនឹងមាត្រា ១៨, ១៩ និង ២០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូច្នេះភស្តុតាងទាំងឡាយណាដែលបានមកពីការរំលោភ នេះ ពុំអាចយកជាការបានឡើយ ។

- ដោយឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកថាឈ្មោះ ស្នេ ហ៊ិនបានប្រព្រឹត្ត អំពើល្មើស ជួញដូរគ្រឿងញៀនខុសច្បាប់ ដែលត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ដែលតាមមាត្រា ២២២ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការកំពូលសំរេច អោយជនជាប់ចោទ រួចខ្លួន ។

- ដោយឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ

១- ទទួលបណ្ដឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ស្នេ ហ៊ិន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣- សំរេចអោយឈ្មោះ ស្នេ ហ៊ិនរួចខ្លួនពីបទចោទ ។

៤- សំរេចដោះលែង ឈ្មោះ ស្នេ ហ៊ិន ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិហ្គាណា ពីការឃុំឃាំង ប្រសិនបើឈ្មោះនេះពុំមានជាប់ពីបទផ្សេងទៀតទេ ។

៥- លិខិតឆ្លងដែនលេខ អា ១៦០១៧២ និង អា ២៣១៨៦០ , កាតលេខ ១៧៣ ១៣៩៨៨ , ខ្សែក្រណើ , ប្រាក់ ចំនួន ៥០ដុល្លាអាមេរិក , កាបូបក្រវ៉ាត់ចង្កេះមួយ , ទូរទស្សន៍ ពណ៌ម៉ាកយូនីលេខ ១០១៦៩៥៦ទំហំ១៤អ៊ិញ១គ្រឿង , ទូរទឹកកកពណ៌ទឹកផ្ទៃមេឃម៉ាកហ្វាស្វ្រីណាស៊ិនអ៊ែរ

៥៦០ ៛ ក្រគ្រឿង និង ម៉ាញេ្យតូសូនី សេរីអេញ្ជ្រអេស ៧៤៥ ១៣០វ៉ាត់ ត្រូវប្រគល់អោយឈ្មោះ ស្មេ ប៊ិន វិញ ។

៦ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ - មិថុនា ឆ្នាំ ១៩៩៩ ។